ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

លេខ ២០០ ដនស/ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យ

## ស្តីពីសម្បទានដីសង្គមកិច្ច

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel/Fax : (855-23) 215 660. e-mail : mlmupc@Camnet.Com.Kh

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សំរេច

### ១.- គោលបំណង

**ប្រការ ១.-**

ប្រកាសនេះ កំណត់គោលការណ៍ណែនាំ និងនីតិវិធីក្នុងការអនុវត្តអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ។

**ប្រការ ២.-**

ដីសម្បទានសង្គមកិច្ច អាចត្រូវបានផ្តល់ឱ្យដល់រូបវន្តបុគ្គល ឬក្រុមមនុស្ស ដែលមានសញ្ជាតិខ្មែរ សម្រាប់គោលដៅសង្គមកិច្ច ដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើន ដូចមានកំណត់ក្នុងមាត្រា ៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ដូចខាងក្រោម ៖

១.- ផ្តល់ដីដល់គ្រួសារក្រីក្រ ដែលគ្មានទីលំនៅ សម្រាប់សង់លំនៅឋាន ។
២.- ផ្តល់ដីដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។
៣.- ផ្តល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅ បណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សម្រាប់ការតាំងលំនៅឋានជាថ្មី ។
៤.- ផ្តល់ដីដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។
៥.- ផ្តល់ដីដល់គ្រួសារទាហានពិការ ពិការ ។
៦.- ផ្តល់ដីដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ។
៧.- ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

៨.-ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ឱ្យដីដល់កម្មករចំការធំៗ សម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៩.-អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប ។

## ខ.-យន្តការសម្បទានដីសង្គមកិច្ច

ប្រការ ៣.-

យន្តការសម្បទានដីសង្គមកិច្ច មានបេសកកម្មផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ច រៀបចំផែនការសម្បទានដីសង្គមកិច្ច និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សំដៅធ្វើការបែងចែកដីឱ្យប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ។

យន្តការសម្បទានដីសង្គមកិច្ច មានដូចតទៅ :

-ក្រុមប្រឹក្សាឃុំ សង្កាត់

-ក្រុមការងារថ្នាក់ស្រុក ខណ្ឌ

-គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង

-គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

តួនាទី ភារកិច្ច និងសមាសភាពរបស់យន្តការសម្បទានដីសង្គមកិច្ចនីមួយៗ មានកំណត់ក្នុងជំពូកទី ៦ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។

## គ.-កម្មវិធីសម្បទានដីសង្គមកិច្ច

ប្រការ ៤.-

កម្មវិធីសម្បទានដីសង្គមកិច្ច មានពីរថ្នាក់គឺ :

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

### ក.- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

ប្រការ ៥.-

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ត្រូវបានផ្តួចផ្តើមឡើង ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់ នៃផែនការសម្បទានដីសង្គមកិច្ច ។

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ក៏អាចត្រូវបានផ្តួចផ្តើមឡើងដោយប្រជាពលរដ្ឋ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះស្ថិតនៅ និងត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ។

ប្រការ ៦.-

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ត្រូវធ្វើប្រចាំឆ្នាំ ដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ត្រូវកំណត់ឱ្យច្បាស់នូវគោលដៅ ដូចបានកំណត់ក្នុងប្រការ ២ ខាងលើ កំណត់អត្តសញ្ញាណដីដែលអាចប្រើប្រាស់បានសម្រាប់សម្បទានដីសង្គមកិច្ច ឬដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ច ពិពណ៌នាអំពីដី និងផែនការប្រើប្រាស់ដី ពិពណ៌នាអំពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ផែនការលំអិតក្នុងការបែងចែកដី រៀបរាប់អំពីដំណើរការដាក់ពាក្យ វាយតម្លៃអំពីលទ្ធភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចាំបាច់ វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន និងតម្រូវការចាំបាច់ផ្សេងទៀតដែលសមស្របនឹងតំបន់ដីសម្បទានសង្គមកិច្ចនោះ ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការណែនាំលំអិតអំពីរបៀប និងលក្ខខណ្ឌនានា ក្នុងការកសាងផែនការសម្បទានដីសង្គមកិច្ច ។

ប្រការ ៧.-

ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការធ្វើអត្តសញ្ញាណកម្មដី ការធ្វើចំណាត់ថ្នាក់ដី ការធ្វើផែនការប្រើប្រាស់ដី ការធ្វើផែនការ និងកំណត់លក្ខណវិនិច្ឆ័យជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។

ប្រការ ៨.-

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ត្រូវបានបញ្ជូនទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង តាមរយៈក្រុមការងារថ្នាក់ស្រុក ខណ្ឌ ដើម្បីសុំការសម្រេចយល់ព្រម ។

ប្រការ ៩.-

បន្ទាប់ពីបានសម្រេចយល់ព្រមហើយ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹងដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យ កែសម្រួលផែនការ ឬលុបចោលសេចក្ដីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្នុងករណីដែលផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ឬមិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ ឬផែនការនោះ មានកំហុសបច្ចេកទេស ឬរំលោភបញ្ញត្តិទាំងឡាយ នៃអនុក្រឹត្យ ឬច្បាប់ផ្សេងៗ ទៀត ។

ការពិនិត្យ កែសម្រួលផែនការ ឬការលុបចោលសេចក្ដីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើឡើងក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ។

## ខ. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

ប្រការ ១០.-

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវបានផ្ដួចផ្ដើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន មិនអាចធ្វើបាន ពិសេសក្នុងស្ថានភាពដូចមានកំណត់ក្នុងប្រការ ៧ នៃអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី ១៩ មីនា ២០០៣ នេះ ដោយត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់ នៃផែនការសម្បទានដីសង្គមកិច្ច ។

ប្រការ ១១.-

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវបញ្ជូនទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ ។

ប្រការ ១២.-

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចផ្ដល់ការយល់ព្រមលើផែនការ ឬ

កសម្រួលផែនការដែលបានស្នើឡើង ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ៤-ភារៈអនុវត្ត

### • ជំហានទី ១ : ការផ្សព្វផ្សាយឱ្យដឹងជាសាធារណៈ

**ប្រការ ១៣.-**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈ នៅសាលាឃុំ សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះស្ថិតនៅ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ រាល់ពេលម៉ោងធ្វើការ ។

ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយត្រូវផ្សព្វផ្សាយទូលំទូលាយ និងជូនដំណឹងដល់ប្រជាពលរដ្ឋ និងមុខសញ្ញាអ្នកទទួលដី អំពីកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន អំពីគោលបំណង និងលក្ខខណ្ឌដែលត្រូវចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនោះ ។

**ប្រការ ១៤.-**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈ នៅសាលាឃុំ សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះស្ថិតនៅ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ រាល់ពេលម៉ោងធ្វើការ ។

ក្រសួង ស្ថាប័ន ឬម្ចាស់សំណើ ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ តាមការកំណត់នៅក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានការកំណត់ច្បាស់លាស់អំពីតួនាទីក្រសួង ស្ថាប័នពាក់ព័ន្ធ ការកំណត់អំពីការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលផ្សេងពីនេះ។

## • ជំហានទី ២ ៖ ការជូនដំណឹងពីការដាក់ពាក្យ

ប្រការ ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកំណត់កាលបរិច្ឆេទ រយៈពេល និងទីកន្លែងនៃការទទួលពាក្យសុំដីសម្បទាន ។ សេចក្តីជូនដំណឹងពីការដាក់ពាក្យសុំដីសម្បទាន ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃ មុនកាលបរិច្ឆេទនៃការទទួលពាក្យសុំ ។ សេចក្តីជូនដំណឹង ត្រូវធ្វើជាចំហ និងត្រូវបិទផ្សាយនៅទីសាធារណៈក្នុងតំបន់ដីសម្បទាននោះ ដូចជា នៅសាលាឃុំ សង្កាត់ ទីវត្តអារាម សាលារៀន ឬទីសាធារណៈផ្សេងៗ ទៀត ។

ក្នុងរយៈពេលជូនដំណឹងនេះ ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបើកកិច្ចប្រជុំជាមួយប្រជាពលរដ្ឋក្នុងតំបន់ដីសម្បទានសង្គមកិច្ច ផ្សព្វផ្សាយអំពីការចាប់ផ្តើមអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ពន្យល់ណែនាំអំពីនីតិវិធីការអនុវត្ត អំពីសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋ អំពីលក្ខខណ្ឌនៃការកាន់កាប់ដី និងបកស្រាយបំភ្លឺនូវរាល់សំណួរ និងចម្ងល់ដែលបានលើក ។

ប្រការ ១៦.-

ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច និងដែលមានបំណងចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវដាក់ពាក្យសុំដីសម្បទានសង្គមកិច្ចនៅសាលាឃុំ សង្កាត់ដែលបានកំណត់ក្នុងសេចក្តីជូនដំណឹង ដោយត្រូវបំពេញពាក្យសុំតាមគំរូក្នុងឧបសម្ព័ន្ធលេខ ១ នៃប្រកាសនេះ ។

អ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវបញ្ជាក់អំពីប្រភេទដីដែលស្នើសុំ ជាដីសម្រាប់សង់លំនៅឋាន ឬជាដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬជាដីទាំងពីរប្រភេទ ។

ប្រការ ១៧.-

ការទទួលពាក្យសុំដីសម្បទានសង្គមកិច្ច មានរយៈពេល ២០ ថ្ងៃ ។

ប្រការ ១៨.-

ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីជំនាញឱ្យចុះជួយក្នុងការងារទទួលពាក្យសុំដីសម្បទានសង្គមកិច្ច ជួយណែនាំក្នុងការបំពេញពាក្យសុំ ការទុកដាក់ឯកសារពាក្យសុំ និងការធ្វើតារាងបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ច ។

ប្រការ ១៩.-

បញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ ដែលបានទទួលក្នុងអំឡុងពេលទទួលពាក្យសុំដីសម្បទានសង្គមកិច្ច ត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ រយៈពេលយ៉ាងតិច ៣០ថ្ងៃ មុនពេលធ្វើការវាយតម្លៃលើពាក្យសុំ ។

ប្រការ ២០.-

បញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ច ត្រូវបើកចំហជាសាធារណៈ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរក្សាទុកបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ច ដែលបានដាក់ពាក្យសុំតាមគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៣ : ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី

ប្រការ ២១.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំដីទាំងអស់ ។ ការសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ហេតុផលនៃការសម្រេចយល់ព្រម ឬមិនយល់ព្រមចំពោះអ្នកសុំដីម្នាក់ៗ និងត្រូវបើកចំហ និងបិទផ្សាយជាសាធារណៈ ។

ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ជំនួយបច្ចេកទេស ក្នុងការវាយតម្លៃលើគ្រប់ពាក្យសុំ ដើម្បីកំណត់ថា អ្នកសុំដីបានបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន ឬភាពអាទិភាពក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ។

អង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសមុខសញ្ញាអ្នកទទួលដីត្រូវត្រួតពិនិត្យការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដោយផ្អែកលើលក្ខណវិនិច្ឆ័យ នៃការជ្រើសរើសកំណត់ក្នុងផែនការសម្បទានដីសង្គមកិច្ច ។

ប្រការ ២២.-

លក្ខណវិនិច្ឆ័យ សម្រាប់ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី មាន :

ក-អ្នកសុំដីត្រូវមានសញ្ជាតិជាខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើជាម្ចាស់ដី,

ខ-អ្នកសុំដីត្រូវតែជាមេគ្រួសារដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាប់សាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាក្នុងលំនៅឋានតែមួយ,

គ-អ្នកសុំដីបំពេញបានតាមលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុ អំពីការវាយតម្លៃប្រាក់ចំណូលស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ,

ឃ-អ្នកសុំដី ពិតជាគ្មានដីផ្សេងទៀត ដែលមានទំហំស្មើ ឬលើសពីការកំណត់ទំហំដីសម្បទានសង្គមកិច្ច ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច,

ង-អ្នកសុំដី ពុំធ្លាប់បានទទួលដីសម្បទានសង្គមកិច្ច,

ច-អ្នកសុំដី បានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួម ក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានយល់ព្រម ។

## ប្រការ ២៣.-

ក្នុងករណីអ្នកសុំដី មានចំនួនច្រើនជាងចំនួនដីសម្បទានសង្គមកិច្ច ផែនការសម្បទានដីសង្គមកិច្ច អាចបញ្ចូលលក្ខណវិនិច្ឆ័យសមហេតុផលសម្រាប់ផ្តល់ភាពអនុគ្រោះក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដោយផ្អែកលើ :

-គ្រួសារធំ ដែលមានសមាជិកចាប់ពី ៦នាក់ឡើងទៅ,

-រយៈពេលដែលគ្រួសារបានរស់នៅក្នុងតំបន់ដីសម្បទាន,

-មេគ្រួសារជាស្ត្រី ជាជនពិការ ជាអតីតយុទ្ធជនដែលពិការ ជាយោធិនរំសាយ ។

## ប្រការ ២៤.-

រយៈពេលនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដី កំណត់ ១៥ថ្ងៃ បន្ទាប់ពីផុតរយៈពេលបិទផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ ។

បន្ទាប់ពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដីត្រូវបានបញ្ចប់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកសាងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និង បញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង ដោយដកស្រង់យកចេញពីបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ ដែលបានទទួលក្នុងអំឡុងពេលទទួលពាក្យសុំដីសម្បទានសង្គមកិច្ច ។

បញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង ត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេល ២០ថ្ងៃ ដើម្បីឱ្យសាធារណៈជន ឬអ្នកដាក់ពាក្យសុំដីដែលពុំមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ឬបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង ធ្វើការជំទាស់តវ៉ា ។ ផុតរយៈពេលនេះ បើគ្មានការជំទាស់តវ៉ាទេ បញ្ជីឈ្មោះដែលបានបិទផ្សាយ ចាត់ទុកជាស្ថាពរ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការផ្តល់ជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ នឹងធ្វើការបែងចែកដីសម្បទានសង្គមកិច្ចនេះ ដល់អ្នកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ។

ប្រការ ២៥.-

អ្នកសុំដី ដែលពុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ហើយជឿជាក់ថាពាក្យសុំរបស់ខ្លួន ត្រូវបានបកស្រាយមិនស្របតាមច្បាប់ភូមិបាល ឬច្បាប់ផ្សេងទៀត អាចស្នើសុំឱ្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មាធិការសម្បទានសង្គមកិច្ចថ្នាក់ជាតិ ពិនិត្យឡើងវិញ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង។

បន្ទាប់ពីបានទទួលពាក្យស្នើសុំពិនិត្យឡើងវិញ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការស៊ើបអង្កេតបណ្តឹង និងចាត់វិធានការសមស្រប ក្នុងរយៈពេលមិនឱ្យលើសពី ៣០ថ្ងៃ ។

ពាក្យបណ្តឹងស្នើសុំពិនិត្យឡើងវិញ និងសេចក្តីបំភ្លឺ ឬសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់នៃតំបន់ដីសម្បទាន ក្នុងរយៈពេលយ៉ាងតិច ៧ថ្ងៃ មុនការបែងចែកដីសម្បទានសង្គមកិច្ច ។

## • ជំពូកទី ៤ : ការបែងចែកដីសម្បទានសង្គមកិច្ច

ប្រការ ២៦.-

បន្ទាប់ពីផុតរយៈពេលបិទផ្សាយបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ក្នុងករណីគ្មានការជំទាស់តវ៉ា ឬបន្ទាប់ពីផុតរយៈពេលបិទផ្សាយសេចក្តីបំភ្លឺ ឬសេចក្តីសម្រេចរបស់គណៈកម្មាធិ-

ការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ឬរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងករណីមានការជំទាស់តវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការបែងចែកដីដល់អ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ។

ប្រការ ២៧.-

ការបែងចែកដីសម្បទានសង្គមកិច្ច ត្រូវបានធ្វើឡើងតាមរយៈការចាប់ឆ្នោតយកលេខក្បាលដី ដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ និងក្រោមការត្រួតពិនិត្យពីអង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសបេក្ខជនសល្បាអ្នកទទួលដី ។

ការចាប់ឆ្នោតយកលេខក្បាលដី ត្រូវបានជូនដំណឹងជាមុនយ៉ាងតិច ៧ ថ្ងៃ មុនកាលបរិច្ឆេទនៃការចាប់ឆ្នោត និងត្រូវធ្វើនៅទីសាធារណៈក្នុងតំបន់ដីសម្បទាន ចំពោះមុខប្រជាពលរដ្ឋ និងអ្នកត្រូវទទួលដីដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ទាំងអស់ ។

ប្រការ ២៨.-

មុនធ្វើការចាប់ឆ្នោតយកលេខក្បាលដី ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការបង្ហាញអំពីប្លង់ក្បាលដីដែលត្រូវបែងចែកក្នុងផែនការសម្បទានដីសង្គមកិច្ច ដែលបានអនុម័តយល់ព្រមហើយ អំពីលេខក្បាលដីដែលត្រូវចាប់ឆ្នោតយក និងអំពីរបៀបចាប់ឆ្នោត ។

ប្រការ ២៩.-

អ្នកមានសិទ្ធិក្នុងការចាប់ឆ្នោតយកលេខក្បាលដី ត្រូវតែជាអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ។ របៀបចាប់ឆ្នោតយកលេខក្បាលដី អាស្រ័យក្រុមប្រឹក្សាឃុំ សង្កាត់ និង ក្រុមការងារថ្នាក់ស្រុក ខណ្ឌ កំណត់តាមភាពជាក់ស្តែង ។

ប្រការ ៣០.-

ក្រោយពេលចាប់ឆ្នោតយកលេខក្បាលដីរួច ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវស្រង់ឈ្មោះ និងលេខក្បាលដីចាប់ឆ្នោតបាន ដោយធ្វើជាបញ្ជីឈ្មោះអ្នកទទួលដី(សម្បទានិក) និងលេខក្បាលដី ។

ប្រការ ៣១.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញមុខសញ្ញាអ្នកទទួលដី ឬសម្បទានិកទាំងអស់មកប្រជុំផ្សព្វផ្សាយអំពីខ្លឹមសារនៃកិច្ចសន្យា ដែលនឹងត្រូវចុះហត្ថលេខាដោយសម្បទានិក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសង្កត់ធ្ងន់អំពីកាតព្វកិច្ចរបស់សម្បទានិកត្រូវបំពេញក្នុងរយៈពេលសម្បទាន អំពីការទទួលបានសិទ្ធិកម្មសិទ្ធិនៅពេលលក្ខខណ្ឌនៃការកាន់កាប់ដីត្រូវបានបំពេញរួច និងអំពីការដកហូតដីវិញ ប្រសិនបើសម្បទានិកមិនបំពេញបានលក្ខខណ្ឌ និងកាតព្វកិច្ចក្នុងកិច្ចសន្យា ។

បន្ទាប់ពីបានពន្យល់ផ្សព្វផ្សាយខ្លឹមសារនៃកិច្ចសន្យារួចហើយ មុខសញ្ញាអ្នកទទួលដី ឬសម្បទានិក ត្រូវចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ តាមគំរូក្នុងឧបសម្ព័ន្ធលេខ ២ នៃប្រកាសនេះ។

កិច្ចសន្យា ត្រូវធ្វើជា ៥ច្បាប់ ដោយ :

- ប្រគល់ឱ្យសម្បទានិក ១ច្បាប់,
- តំកល់នៅសាលាឃុំ សង្កាត់ ១ច្បាប់,
- តំកល់នៅសាលាស្រុក ខណ្ឌ(ក្រុមការងារថ្នាក់ស្រុក ខណ្ឌ) ១ច្បាប់,
- តំកល់នៅសាលាខេត្ត ក្រុង(គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង) ១ច្បាប់,
- តំកល់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ) ១ច្បាប់ ។

ប្រការ ៣២.-

បន្ទាប់ពីសម្បទានិក និងក្រុមប្រឹក្សាឃុំ សង្កាត់ ចុះហត្ថលេខាលើកិច្ចសន្យាហើយ កិច្ចសន្យាសម្បទាននោះ ត្រូវចាត់ទុកជាផ្លូវការ ដែលភាគីហត្ថលេខីត្រូវអនុវត្តតាម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ និងក្រោមការណែនាំពីអង្គភាពគាំទ្របច្ចេកទេសការងារដីធ្លី ត្រូវនាំសម្បទានិក ទៅបង្ហាញក្បាលដី និងប្រគល់ក្បាលដីនោះ ជូន ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវចេញលិខិតបញ្ជាក់សម្បទានដីសង្គមកិច្ច ជូនដល់គ្រប់សម្បទានិក នៃក្បាលដីទាំងអស់ ។

## ជំពូកទី ៥ ៖ ការតាមដាន និងវាយតម្លៃការអនុវត្ត

### ប្រការ ៣៣.-

ក្រោយពីកិច្ចសន្យាសម្បទានដីសង្គមកិច្ចចូលជាធរមាន និងក្រោយពីបានប្រគល់ ទទួលបាលដីរួច ក្រុមការងារស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលការងារ ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ។

### ប្រការ ៣៤.-

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋាន សម្បទានិកត្រូវសាងសង់លំនៅឋានឬយ៉ាងហោចណាស់ចំណែកណាមួយនៃជំរកស្នាក់នៅ ក្នុងរយៈពេល ៣ខែបន្ទាប់ពីបានទទួលដី ហើយសម្បទានិក ឬសមាជិកនៃគ្រួសារខ្លួនត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍នៅលើដីនោះ យ៉ាងតិច ៦ខែ ក្នុង ១ឆ្នាំ ។

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ សម្បទានិកត្រូវធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះ ក្នុងរយៈពេល ១២ខែ បន្ទាប់ពីបានទទួលដី និងបន្តប្រើប្រាស់ដីនោះ ស្របតាមលក្ខខណ្ឌចាំបាច់នៃកម្មវិធីសម្បទាន ។

បន្ទាប់ពីបានអនុវត្តត្រឹមត្រូវតាមកម្មវិធីសម្បទានដីសង្គមកិច្ចបាន ៥ឆ្នាំ សម្បទានិក មានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិ តាមនីតិវិធីកំណត់ ។

### ប្រការ ៣៥.-

ក្នុងរយៈពេល ៥ឆ្នាំ ដំបូង នៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សម្បទានិក មិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានសង្គមកិច្ចនេះ បានឡើយ ។ កិច្ចសន្យាលក់ ដូរ ជួល ឬអោយ ដែលធ្វើក្នុងរយៈពេល ៥ឆ្នាំដំបូងនេះ ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ។

ប៉ុន្តែប្រសិនបើក្នុង រយៈពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សម្បទានិកបានទទួលមរណភាព សហព័ទ្ធ ដែលនៅរស់ ឬទាយាទរបស់សម្បទានិក អាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះ រហូតដល់គ្រប់ ៥ឆ្នាំ ហើយមានសិទ្ធិកម្មសិទ្ធិលើដីនោះ ។

### ប្រការ ៣៦.-

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋាន ក្នុងរយៈពេល ១ខែ បន្ទាប់ពីបាន

ទទួលដី ប្រសិនបើសម្បទានិក មិនបានធ្វើការសាងសង់លំនៅឋាន ឬចំណែកណាមួយនៃជំរកស្នាក់នៅទេ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹងដល់សម្បទានិក ឱ្យអនុវត្តលក្ខខណ្ឌនៃការកាន់កាប់ដីតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ។ សេចក្តីជូនដំណឹងជាលើកទី ២ នឹងត្រូវបានធ្វើនៅពេលសម្បទានិក មិនបានធ្វើការសាងសង់លំនៅឋាន ឬចំណែកណាមួយនៃជំរកស្នាក់នៅ ក្នុងរយៈពេល ២ខែ បន្ទាប់ពីបានទទួលដីសម្បទាន ។

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ក្នុងរយៈពេល ៦ខែ បន្ទាប់ពីបានទទួលដី ប្រសិនបើសម្បទានិក មិនបានរៀបចំដី ដើម្បីធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះទេ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងត្រូវជូនដំណឹងដល់សម្បទានិក ឱ្យអនុវត្តលក្ខខណ្ឌនៃការកាន់កាប់ដី តាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ។ សេចក្តីជូនដំណឹងជាលើកទី ២ នឹងត្រូវបានធ្វើ នៅពេលសម្បទានិក មិនបានរៀបចំដីដើម្បីធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះក្នុងរយៈពេល ៩ខែ បន្ទាប់ពីបានទទួលដីសម្បទាន។

ប្រការ ៣៧.-

ប្រសិនបើសម្បទានិក ខកខានមិនបានបំពេញតាមលក្ខខណ្ឌ នៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងធ្វើការដកហូតដីសម្បទាននោះ ដើម្បីយកទៅបែងចែកដល់មុខសញ្ញាអ្នកទទួលដី ក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង ។

ប្រការ ៣៨.-

ការដកហូតដី ត្រូវជូនដំណឹងដល់សម្បទានិក ក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃប្រកាសដកហូត ដោយក្នុងសេចក្តីសម្រេចប្រកាសដកហូត ត្រូវមានបញ្ជាក់អំពីមូលហេតុ។ សម្បទានិកមានសិទ្ធិឆ្លើយតប ក្នុងរយៈពេលនេះ អំពីមូលហេតុដែលខ្លួន ខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដោយត្រូវមានអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ។

សេចក្តីជូនដំណឹងពីការប្រកាសដកហូតដីសម្បទាន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃប្រកាសដកហូត។ ផុតរយៈពេលនេះ បើគ្មានបណ្តឹងឆ្លើយតបពីសម្បទានិក ដែលត្រូវបានដកហូតទេ ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងចាត់បែងចែកដីនោះ ឱ្យមុខសញ្ញាអ្នកទទួលដីក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបំរុង តាមនីតិវិធី ដូចការបែងចែកលើកដំបូង ។

ក្នុងករណីមានបណ្ដឹងឆ្លើយតបពីសម្បទានិក ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើការស៊ើបអង្កេត និងលើកយោបល់ទៅគណៈ-កម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីពិនិត្យ និងសម្រេច ។

ប្រការ ៣៩.-

ប្រកាសនេះ ត្រូវអនុវត្តក្នុងតំបន់ដីពីសមួយចំនួន ដែលនឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រមូលនូវបទពិសោធន៍ក្នុងការអនុវត្តជំហានដំបូង ធ្វើការកែលំអ ឈានទៅអនុវត្តទូលំទូលាយទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤០.-

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អគ្គនាយក គ្រប់អគ្គនាយកដ្ឋាន ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ប្រធានក្រុមការងារថ្នាក់ស្រុក ខណ្ឌ និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកាឆ្នាំ ២០០៣

រដ្ឋមន្ត្រី

[illegible]

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៤០
- ឯកសារ កាលប្បវត្តិ